# ការធ្វើតេស្តរកCoronavirus (COVID-19)

ប្រសិនបើអ្នកមានសំណួរអំពី coronavirus (COVID-19) សូមទូរសព្ទទៅខ្សែទូរសព្ទបន្ទាន់ coronavirus ដែលមាន 24-ម៉ោង តាមលេខ 1800 675 398។

ដើម្បីស្វែងរកកន្លែងដែលអ្នកអាចទៅដើម្បទទួលការធ្វើតេស្តរក coronavirus អ្នកអាចហៅទូរសព្ទទៅខ្សែទូរសព្ទបន្ទាន់ coronavirus ដែលមាន 24-ម៉ោង តាមលេខ 1800 675 398 ឬចូលមើល https://www.dhhs.vic.gov.au/getting-tested-coronavirus-covid-19។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ មុនដំបូងសូមទូរសព្ទទៅលេខ 131 450 បន្ទាប់មកស្នើសុំទៅខ្សែទូរសព្ទបន្ទាន់ coronavirus ឬស្នើសុំពួកគេឱ្យមើលគេហទំព័រសម្រាប់អ្នក។

អ្នកអាចរកមើលឯកសារផ្សេងៗបន្ថែមទៀត ដែលបានបកប្រែរួចជាស្រេចនៅគេហទំព័រ https://www.coronavirus.vic.gov.au/translations។

## ការធ្វើតេស្តរក Coronavirus មិនគិតថ្លៃសម្រាប់ពលរដ្ឋគ្រប់រូបនៅរដ្ឋវិកថូរៀ(Victoria) ដោយរួមទាំងនិស្សិតអន្តរជាតិ អ្នកដែលកំពុងស្វែងរកសិទ្ធិជ្រកកោន ឬអ្នកមកលេងពីបរទេស

ការធ្វើតេស្តរក coronavirus មិនគិតថ្លៃសម្រាប់មនុស្សគ្រប់រូប។ នេះរួមមានអ្នកគ្មានកាត Medicare ដូចជាអ្នកមកលេងអូស្ត្រាលី ដែលមកពីបរទេស និស្សិតអន្តរជាតិ កម្មករអន្តោប្រវេសន៍ និងអ្នកស្វែងរកសិទ្ធិជ្រកកោន។

ប្រសិនបើអ្នកមានរោគសញ្ញា អ្នកអាចទទួលការធ្វើតេស្តដោយឥតគិតថ្លៃនៅទីតាំងណាមួយនៃបណ្តាទីតាំងដូចតទៅ៖

- មន្ទីរពេទ្យ coronavirus រដ្ឋវិកថូរៀ (គ្លីនិកវាយតម្លៃជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ,Acute Respiratory Assessment Clinic)
- គ្លីនិកវាយតម្លៃជំងឺផ្លូវដង្ហើម តាមសហគមន៍ (Community Health Centre Respiratory Assessment Clinic)
- គ្លីនិកដែលអាចបើកឡានឆ្លងកាត់បាននៅមជ្ឈមណ្ឌលទិញទំនិញ
- គ្លីនិកដែលអាចដើរចូលបាននៅតាមតំបន់។

## តើអ្នកណាខ្លះគួរធ្វើតេស្តរក Coronavirus?

អ្នកគួរតែទៅធ្វើតេស្តរក coronavirus ប្រសិនបើអ្នកមានរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាដូចទៅនេះ៖

- គ្រុន
- គ្រុនរងារ
- ក្អក
- ឈឺបំពង់ក
- ដង្ហើមខ្លី
- ហៀរសំបោរ
- បាត់បង់ការដឹងក្លិន

បើទោះបីរោគសញ្ញារបស់អ្នកស្រាលក៏ដោយ អ្នកគួរតែធ្វើតេស្ត។



Victoria State Government | Health and Human Services

## តើមានអ្វីខ្លះកើតឡើងនៅពេលអ្នកទទួលបានការធ្វើតេស្ត?

នៅពេលអ្នកទៅទទួលការធ្វើតេស្ត គេនឹងសួររកប័ណ្ណកំណត់អត្តសញ្ញាណ និងព័ត៌មានសម្រាប់ទំនាក់ទំនង។ ប្រសិនបើអ្នកគ្មានកាត Medicare ទេ សូម យកនូវប័ណ្ណសំគាល់អត្តសញ្ញាណ ឧទាហរណ៍ប័ណ្ណបើកបរ លិខិតឆ្លងដែន កាតបញ្ចុះតម្លៃក្នុងការធ្វើដំណើរ ឬប័ណ្ណសំគាល់និស្សិតជាដើម។ គ្លីនិកធ្វើតេស្តមិនត្រូវការដឹងអំពីស្ថានភាពទិដ្ឋាការរបស់អ្នកទេ។

ការធ្វើតេស្តរក coronavirus ត្រូវបានធ្វើឡើងដោយគិលានុបដ្ឋាយិកា វេជ្ជបណ្ឌិត ឬអ្នកជំនាញសុខភាពផ្សេងទៀត។ ពួកគេនឹងផ្តិតយកសំណាកទន់ស្អិតនៅផ្នែកខាងក្រោយនៃបំពងក និងច្រមុះរបស់អ្នក។ ការធ្វើតេស្តចំណាយពេលប្រហែលមួយនាទី។

## តើខ្ញុំត្រូវការដាក់ខ្លួនឯងឱ្យនៅដោយឡែកពីគេ ក្រោយពី ធ្វើតេស្តរក Coronavirus ឬទេ?

ប្រសិនបើអ្នកមានរោគសញ្ញា វេជ្ជបណ្ឌិត ឬបុគ្គលិកថែទាំសុខភាពនឹងប្រាប់អ្នក ឱ្យនៅដោយឡែកពីគេ រហូតដល់អ្នកទទួលបានលទ្ធផល។ នេះមានន័យថាអ្នកត្រូវទៅផ្ទះភ្លាមក្រោយការធ្វើតេស្ត និងត្រូវស្នាក់នៅផ្ទះរហូតដល់អ្នកដឹងលទ្ធផល។

វេជ្ជបណ្ឌិតរបស់អ្នក ឬគ្លីនិកនៅកន្លែងដែលអ្នក បានទៅធ្វើតេស្តនឹងទាក់ទងអ្នកដើម្បីប្រាប់ថាតើអ្នកមាន coronavirus ឬអត់។

## តើត្រូវការរយៈពេលប៉ុន្មានដើម្បីទទួលបានលទ្ធផល?

ជាធម្មតាវាត្រូវការ 1-3 ថ្ងៃដើម្បីទទួលបានលទ្ធផល ក្រោយពីការធ្វើតេស្ត។ ប្រសិនបើមានមនុស្សច្រើនកំពុងធ្វើតេស្ត វាអាចចំណាយពេលរហូតដល់ 5 ថ្ងៃ ដើម្បីទទួលបានលទ្ធផល។

ប្រសិនបើអ្នកមានសំណួរអំពីលទ្ធផលរបស់អ្នក សូមទាក់ទងគ្លីនិក ឬមន្ទីរពេទ្យនៅកន្លែងដែលអ្នកបានធ្វើតេស្ត។

ប្រសិនបើអ្នកត្រូវបានធ្វើតេស្តនៅគ្លីនិកបើកឆ្លងកាត់នៅឯមជ្ឈមណ្ឌលទិញទំនិញ ហើយបានរង់ចាំលទ្ធផលធ្វើតេស្តរបស់អ្នកលើសពី 5 ថ្ងៃ សូមទាក់ទងខ្សែទូរសព្ទបន្ទាន់ coronavirus តាមលេខ 1800 675 398។ ក្រុមរបស់យើងនឹងជួយអ្នកដើម្បីទទួលបានលទ្ធផលរបស់អ្នក។ គ្លីនិកបើកឆ្លងកាត់នៅឯមជ្ឈមណ្ឌលទិញទំនិញមិនអាចជួយអ្នកទទួលបានលទ្ធផលធ្វើតេស្តរបស់អ្នកបានទេ ដូច្នេះសូមកុំទាក់ទងពួកគេដើម្បីសុំលទ្ធផល។

គេនឹងប្រាប់អ្នក ពីលទ្ធផលធ្វើតេស្ត ទោះបីលទ្ធផលបង្ហាញថាគ្មានមេរោគក៏ដោយ។ប្រសិនបើលទ្ធផលធ្វើតេស្តរបស់អ្នកវិជ្ជមាន (មានមេរោគ) បុគ្គលិក Department of Health and Human Services នឹងទាក់ទងអ្នកដើម្បីស្នើសុំព័ត៌មានបន្ថែម និងប្រាប់អ្នកត្រូវធ្វើអ្វីទៀត។

ដើម្បីទទួលបានការបោះពុម្ពផ្សាយនេះជាទម្រង់ដែលអាចចូលប្រើបាន សូមអ៊ីមែលទៅ Emergency Management Communications <em.comms@dhhs.vic.gov.au>.

Authorised and published by the Victorian Government, 1 Treasury Place, Melbourne.

© State of Victoria, Australia, Department of Health and Human Services May 2020.

ISBN/ISSN 978-1-76069-423-4 (online/print)

Available at Translated resources - coronavirus disease (COVID-19) <https://www.dhhs.vic.gov.au/translated-resources-coronavirus-disease-covid-19>